ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខៈ..០១៧..សកបយ.

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដល់ សហព័ន្ធសហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និងនិយោជកនៃរោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើងទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០០ គណៈកម្មការប្រឹក្សាការងារ ដែលមានតំណាងមកពីខាងរាជរដ្ឋាភិបាល តំណាងមកពីខាងសហព័ន្ធសហជីពកម្មករនិយោជិត និងតំណាងមកពីខាងសមាគមនិយោជក បានធ្វើការប្រជុំពិភាក្សាគ្នាអំពីប្រាក់ឈ្នួលអប្បបរមា របស់កម្មករនិយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើង ។ ការប្រជុំនោះសំរេចបានលទ្ធផលដូចតទៅ :

១-យោងសភាពការណ៍ជាក់ស្តែងចំពោះមុខ ហើយនិងយោងតាមទឡ្ហីករណ៍ដែលលើកឡើងដោយតំណាងកម្មករនិយោជិត និងដោយតំណាងនិយោជក ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មករនិយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើង គឺកំណត់ស្មើនឹង ៤០ ដុល្លារ អាមេរិកក្នុងមួយខែ ក្នុងរយៈពេលដែលកម្មករនិយោជិតធ្វើការសាកល្បងការងារពី ១ ខែទៅ ៣ ខែ ។ ចំពោះកម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល ( ដេរស៊ីបុង ) ត្រូវបានប្រាក់ឈ្នួលតាមលទ្ធផលជាក់ស្តែងដែលធ្វើបាន ។ បើទិន្នផលការងារទទួលបានប្រាក់ឈ្នួលលើសពី ៤០ ដុល្លារ អាមេរិកក្នុងមួយខែ គឺត្រូវទទួលតាមការលើសនោះ ។ តែបើបានទាបជាង ៤០ ដុល្លារ អាមេរិកក្នុងមួយខែ និយោជកត្រូវបន្ថែមអោយគ្រប់ ៤០ ដុល្លារ អាមេរិកក្នុងមួយខែ ។

២- ចប់រយៈពេលសាកល្បង កម្មករនិយោជិតដែលពេញសិទ្ធិហើយ គឺត្រូវទទួលបានប្រាក់ឈ្នួលអប្បបរមា ៤៥ ដុល្លារ អាមេរិកក្នុងមួយខែ ។ ចំពោះកម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល ( ដេរស៊ីបុង ) ត្រូវបានប្រាក់ឈ្នួលតាមលទ្ធផលជាក់ស្តែងដែលធ្វើបាន ។ បើទិន្នផលការងារទទួលបានប្រាក់ឈ្នួលលើសពី ៤៥ ដុល្លារ អាមេរិកក្នុងមួយខែ គឺត្រូវទទួលតាមការលើសនោះ ។ តែបើបានទាបជាង ៤៥ ដុល្លារ អាមេរិកក្នុងមួយខែ និយោជកត្រូវបន្ថែមអោយគ្រប់ ៤៥ ដុល្លារ អាមេរិកក្នុងមួយខែ ។

៣-កម្មករនិយោជិត ដែលធ្វើការទៀងទាត់នៃចំនួនថ្ងៃដែលត្រូវធ្វើការក្នុងមួយខែ១នោះ ត្រូវបានប្រាក់រង្វាន់យ៉ាងតិចចំនួន ៥ ដុល្លារ អាមេរិកក្នុងមួយខែ ។

៤- កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ១.០០០ រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ។

៥-កម្មករនិយោជិត ដែលធ្វើការបានយូរឆ្នាំទៅក្នុងរោងចក្រ សហគ្រាសណាមួយ ត្រូវបានប្រាក់រង្វាន់ការងារដូចតទៅ :

៥.១- ធ្វើការបានចាប់ពីមួយឆ្នាំឡើងទៅត្រូវទទួលបានប្រាក់រង្វាន់អតីភាពការងារចំនួន ២ ដុល្លារ អាមេរិកក្នុងមួយខែ ។

៥.២- ធ្វើការបានចាប់ពីពីរឆ្នាំឡើងទៅត្រូវទទួលបានប្រាក់រង្វាន់អតីភាពការងារចំនួន ៣ ដុល្លារ អាមេរិកក្នុងមួយខែ ពោលគឺ ២ ដុល្លារនៃឆ្នាំទី១ បូកនិង ១ ដុល្លារនៃឆ្នាំទី២ ។

៥.៣- ធ្វើការបានចាប់ពីបីឆ្នាំឡើងទៅត្រូវទទួលបានប្រាក់រង្វាន់អតីភាពការងារចំនួន ៤ ដុល្លារ អាមេរិកក្នុងមួយខែ ពោលគឺ ២ ដុល្លារនៃឆ្នាំទី១ បូកនិង ១ ដុល្លារនៃឆ្នាំទី២ បូកនិង ១ ដុល្លារនៃឆ្នាំទី៣ ។

៥.៤- ធ្វើការបានចាប់ពីបួនឆ្នាំឡើងទៅត្រូវទទួលបានប្រាក់រង្វាន់អតីភាពការងារចំនួន ៥ ដុល្លារ អាមេរិកក្នុងមួយខែ ពោលគឺ ២ ដុល្លារនៃឆ្នាំទី១ បូកនិង ១ ដុល្លារនៃឆ្នាំទី២ បូកនិង ១ ដុល្លារនៃឆ្នាំទី៣ បូកនិង ១ ដុល្លារនៃឆ្នាំទី៤ ។

អតីតភាពសំរាប់គិតផ្តល់ប្រាក់រង្វាន់ខាងលើនេះ ត្រូវគិតចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០តទៅ ។

៦- និយោជកត្រូវអនុញ្ញាតអោយកម្មករនិយោជិតឈប់សំរាកប្រចាំឆ្នាំ អោយបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ពោលគឺកម្មករនិយោជិតដែលធ្វើការបានទៀងទាត់ក្នុងរយៈពេល ១២ ខែត្រូវបានឈប់សំរាកប្រចាំឆ្នាំចំនួន ១៨ ថ្ងៃ ។

ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០ តទៅ ប្រាក់ឈ្នួលអប្បបរមា ប្រាក់រង្វាន់ការងារទៀងទាត់ ប្រាក់ថ្លៃបាយ ឬការផ្តល់ជូនបាយមួយពេលសំរាប់កម្មករនិយោជិតធ្វើការបន្ថែមម៉ោង និងប្រាក់រង្វាន់ការងារយូរឆ្នាំរបស់កម្មករនិយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើង ត្រូវអនុវត្តតាមខ្លឹមសារនៃចំណុចទាំងអស់ខាងលើ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងគណៈកម្មការប្រឹក្សាការងារ នឹងបន្តខិតខំបំពេញនូវភារកិច្ចរបស់ខ្លួន អោយស្របតាមតួនាទីដូចដែលមានចែងក្នុងច្បាប់របស់រដ្ឋ ពិសេសគឺច្បាប់ស្តីពីការងារ សំដៅថែរក្សាផលប្រយោជន៍សមស្រប យុត្តិធម៌ នៃរាល់ភាគីពាក់ព័ន្ធអោយកាន់តែល្អប្រសើរឡើងជាលំដាប់ ។

ភ្នំពេញថ្ងៃទី 18 ខែកក្កដាឆ្នាំ ២០០០

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

<u>ចម្លងជូន:</u>

- -ខុទ្ទកាល័យព្រះមហាក្សត្រ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"
- -គ្រប់បណ្តាញទូរទស្សន៍ និងវិទ្យុ "ដើម្បីផ្សព្វផ្សាយ"
- -គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
- -គ្រប់សហព័ន្ធសហជីព
- -គ្រប់សមាគមនិយោជក "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ